**BMI0166**

# សម្ភាសន៍ជាមួយឈ្មោះ អ៊ី យឿត ភេទស្រី អាយុ៩៥ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កងចល័ត

## រស់នៅភូមិស្រែះខាងកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥០:២៣

២៦ទំព័រ

វណ្ណៈ ខ្ញុំឈ្មោះ សុខ វណ្ណៈ មកអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំមកដល់ភូមិឃុំរបស់មីង គឺស្រាវជ្រាវចង់ដឹងរឿងទាក់ទងនឹងរអាងត្រពាំងថ្ម ទំនប់អាងត្រពាំងថ្ម តើនៅទីនោះបងប្អូនយើងជួបការលំបាកយ៉ាងម៉េចខ្លះ អ្នកមកពីភ្នំពេញធ្វើការនៅហ្នឹងមានស្លាប់ ហើយដូចជាអ្នកមូលដ្ឋានដែរអត់អីអញ្ចឹងណា៎មីង ចង់ដឹងរឿងរ៉ាវទាំងអស់ហ្នឹង ចង់ដឹងថាធ្វើហ្នឹងតើការហូបចុកអីដាក់កម្រិតយើងយ៉ាងម៉េច កម្លាំងពលកម្មអីយ៉ាងម៉េច ដាក់ផែនការយ៉ាងម៉េច ទំនប់ហ្នឹងលើកបានរយៈពេលប៉ុន្មានឆ្នាំអីហ្នឹង ខ្ញុំចង់បានពត៌មានទាំងអស់ហ្នឹងគឺចង់យកទៅចងក្រងទុកជាឯកសារប្រវត្តិសាស្រ្ត ដើម្បីក្មេងជំនាន់ក្រោយបានដឹងបានឮ អញ្ចឹងជាដំបូង ខ្ញុំចង់ស្គាល់ឈ្មោះមីង តើមីងឈ្មោះអីដែរ?

យឿតៈ ឈ្មោះ អ៊ី យឿត។

វណ្ណៈ អាយុប៉ុន្មានហើយ?

យឿតៈ អាយុ៩១។

វណ្ណៈ ប្តីរបស់មីងឈ្មោះអីដែរ?

យឿតៈ សំ យោ។

វណ្ណៈ គាត់អាយុប៉ុន្មានហើយ?

យឿតៈ គាត់អាយុ៩០ គាត់អាយុប្អូនខ្ញុំមួយឆ្នាំ។

វណ្ណៈ ចុះមីងសព្វថ្ងៃមានកូនប៉ុន្មាននាក់?

យឿតៈ កូន៨នាក់។

វណ្ណៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យឿតៈ ស្រីទាំង៨នាក់។

វណ្ណៈ ស្រីទាំង៤នាក់ អត់មានប្រុសមួយទេ?

យឿតៈ អត់មានទេ ។

វណ្ណៈ ឪពុកមីងឈ្មោះអីដែរ?

យឿតៈ ឈ្មោះ ភ្ញាំ យុន ។

វណ្ណៈ ចុះម្ដាយ?

យឿតៈ ម្ដាយខ្ញុំឈ្មោះ ឈ្វាក អៀម តែគាត់ស្លាប់ហើយ ។

វណ្ណៈ អញ្ចឹងឪពុកនៅទេ ស្លាប់ម្ដាយ?

យឿតៈ ឪពុកខ្ញុំនៅទេ ។

វណ្ណៈ ម្ដាយស្លាប់ពេលណា?

យឿតៈ បានពាឆ្នាំៗនេះហើយ ។

វណ្ណៈ បងប្អូនបង្កើតរបស់មីងមានប៉ុន្មាននាក់ដែរ?

យឿតៈ បងប្អូនខ្ញុំ៨នាក់ ។

វណ្ណៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

យឿតៈ ប្រុស៥នាក់ ហើយស្រី៣នាក់ ។

វណ្ណៈ អញ្ចឹងសព្វថ្ងៃនៅរស់ទាំងអស់ឬក៏មានស្លាប់ដែរ?

យឿតៈ បងប្អូនខ្ញុំនៅរស់ទាំងអស់ ។

វណ្ណៈ ចុះកាលពីដើមមីងនៅភូមិកំណើត តើមីងនៅភូមិឃុំណាដែរ?

យឿតៈ នៅភូមិស្រែះនេះឯង ។

វណ្ណៈ អាហ្នឹងគេហៅថាភូមិស្រែះខាងលិច?

យឿតៈ ចា៎!

វណ្ណៈ ឃុំ?

យឿតៈ ឃុំព្រះនេត្រព្រះ ។

វណ្ណៈ ស្រុក?

យឿតៈ ព្រះនេត្រព្រះដែរ ។

វណ្ណៈ ចុះខេត្ត?

យឿតៈ ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ ពីដើមកាលសម័យលន់ នល់ សម័យសីហនុខេត្តអីវិញ?

យឿត៖ ខេត្តបាត់ដំបង ។

វណ្ណៈ អញ្ចឹងគេបំបែកខេត្តហ្នឹងមីងចាំទេនៅឆ្នាំណា ដែលគេបំបែកទៅជាខេត្តបន្ទាយមានជ័យវិញ?

យឿត៖ ខ្ញុំអត់បានចាំផង ។

វណ្ណៈ មីងអត់ចាំទេ?

យឿត៖ ចា៎! អត់បានចាំទេ ខ្ញុំមិនបានដាចាប់អារម្មណ៍ទេ អាងតែមានធ្វើការងារ ។

វណ្ណៈ ចុះកាលពីតូចមីងមានបានរៀនសូត្រទេ?

យឿត៖ ខ្ញុំរៀន ។

វណ្ណៈ រៀនបានថ្នាក់ទីប៉ុន្មាន?

យឿត៖ ថ្នាក់ទី១០ តែអត់មានបានទៅរៀនសាលាណាទេ រៀននៅសាលាស្រែះនេះឯង រៀនទៅកាលហ្នឹងយើងហៅទី១១-១២-១០ ។

វណ្ណៈ គេហៅទី១០ចាស់?

យឿត៖ ចា៎!

វណ្ណៈ រៀនបានថ្នាក់ទី១០ ម៉េចបានឈប់រៀន?

យឿត៖ កាលហ្នឹងអត់មានសាលាទេ ។

វណ្ណៈ ស្រុកកើតសង្គ្រាមឬក៏យ៉ាងម៉េច?

យឿត៖ ចា៎! ទៅរៀនថ្ងៃនេះក៏ខានស្អែកទៅ រៀនមួយថ្ងៃខាន១០ថ្ងៃអញ្ចឹងទៅ ។

វណ្ណៈ ម៉េចបានខាន?

យឿត៖ អត់មានគ្រូបង្រៀនទេ អត់សំបូរដូចគ្រូសព្វថ្ងៃទេ ខ្ញុំរៀននេះឯងសាលាចាស់ ។

វណ្ណៈ អញ្ចឹងកាលនៅរៀនមីងមានដូចថា កាលហ្នឹងចលនាទម្លាក់សម្ដេចសីហនុ រដ្ឋប្រហារឆ្នាំ៧០អីមីងមានបានដឹងទេ?

យឿត៖ ខ្ញុំដូចចាំមិនបានទេ ។

វណ្ណៈ ចុះពេលសម័យទម្លាក់គ្រាប់បែកមានចាំទេ?

យឿត៖ ដែលខ្ញុំរៀនសម័យលន់ នល់ អាហ្នឹងខ្ញុំរៀន តែខ្ញុំចាំតែប៉ុណ្ណឹង ស្អីផ្សេងទៀតខ្ញុំអត់ចាំទេ ។

វណ្ណៈ ចុះសម័យគេទម្លាក់គ្រាប់បែក លន់ នល់ គ្រាប់បែក?

យឿត៖ សម័យគេទម្លាក់គ្រាប់បែកខ្ញុំនៅប៉ុនកូនខ្ញុំមីតូចនេះ ។

វណ្ណៈ អាយុប្រហែលជាប៉ុន្មានឆ្នាំ?

យឿតៈ អាយុ១២-១៣ហ្នឹង រត់ទៅអត់មានបាននៅស្រុកភូមិទេ ជិះទូករត់ទៅស្រុកគេនោះ។

វណ្ណៈ ម៉េចបានជាអត់ហ៊ាននៅភូមិហ្នឹង?

យឿតៈ គេផ្ទោងគ្រាប់បែកអត់ហ៊ាននៅ ចូលត្រង់សេគាត់ខ្លាចព្រោះអាពតនៅក្នុងភូមិនេះឯង គេផ្ទោងគ្រាប់បេមកពីព្រះនេត្រព្រះមកពីឃុំណា៎ ភូមិខ្ញុំនេះចេញទៅសរម៉ោពអ៊ុំទូកខែវស្សា និយាយពីខ្លាចមិនហ៊ាននៅភូមិទេ ខ្លាចគ្រាប់ផ្ទោងមកចំ ប្រជាជនចេញអស់ ចុះពួកខ្មែរក្រហមវាចូលនៅនេះឯង អាពតវាចូលមកនៅនេះក៏ប្រជាជនចេញអស់ អត់ហ៊ាននៅទេ។

វណ្ណៈ ចុះឆ្នាំណាបានប្រជាជនចូលមកវិញ?

យឿតៈ មិនដឹងឆ្នាំប៉ុន្មានទេ ទាល់តែចប់ ទាល់តែពួកខ្មែរក្រហមចេញពីភូមិហ្នឹងទៅអស់វិញទៅបានប្រជាជនចូលមកនៅនេះវិញ។

វណ្ណៈ អញ្ចឹងមិនថាពេលចប់លន់ នល់ ពេលចប់អីទៅខ្មែរក្រហមកាន់កាប់ទូទាំងប្រទេសឆ្នាំ៧៥ហ្នឹង បានចូលមកវិញ?

យឿតៈ ចា៎! កាលសម័យលន់ នល់ រត់ដែរតែរត់មិនបានយូទេ រត់៤-៥ថ្ងៃពេលគេចេញអស់ទៅយើងក៏ចូលមកនៅភូមិយើងវិញ ដល់ពេលគេចូលមកយើងចេញទៅទៀត ព្រោះយើងខ្លាច គ្រាប់ផ្ទោងមកចំអត់ហ៊ាននៅទេ។

វណ្ណៈ ប៉ុន្តែលែងឈប់គ្រាប់បែកហើយ ដូចថា?

យឿតៈ ដល់លែងឈប់គ្រាប់បែកហើយ អាពត វាចូលមកយើងនៅនេះហើយ នៅជាមួយវានេះហើយ។

វណ្ណៈ ចុះមកវិញពេលណា ប្រហែលជាត្រលប់ ដូចថាចេញទៅខ្លាចគ្រាប់បែក បានប៉ុន្មានឆ្នាំបានចូលមកវិញ?

យឿតៈ អត់យូទេអូន ចេញទៅតែ៤-១០ថ្ងៃហ្នឹងមកវិញហើយ។

វណ្ណៈ អញ្ចឹងដល់ពេលទម្លាក់មកទៀតរត់ទៀត?

យឿតៈ អត់ទេ ដល់ពេលនេះទៅគេវ៉ៃគ្នាទៅ គេវ៉ៃគ្នាឆ្ងាយៗទៅនៅនេះក៏ផុតទៅ អត់សូវមានវ៉ៃទេ មិនចេញទៅឆ្ងាយទេ ចេញទៅជិតៗនេះឯងហ មិនចេញឆ្ងាយទេ ភូមិនេះមិនដែលបានរត់ទៅណាឆ្ងាយទេ ក្តុងក្តាំងតែប៉ុន្មានថ្ងៃក៏ចេញទៅវិញអស់ ហើយយើងក៏ចូលមកវិញមក។

វណ្ណៈ អញ្ចឹងបើគេចូលមកទៀតយើងចេញទៅទៀតទៅ?

យឿតៈ គេចូលមកយើងចេញទៅទៀត យើងខ្លាចយើងអត់ហ៊ាននៅទេព្រោះយើងខ្លាច។

វណ្ណៈ	អញ្ចឹងពេលឆ្នាំ៧៥ ខ្មែរក្រហមកាន់ទូទាំងប្រទេសហ្នឹង អាហ្នឹងពេលហ្នឹងទាហានលន់ នល់ត្រូវដាក់អាវុធចុះហើយ ហើយគេចាប់គេអីហើយ អញ្ចឹង៧៥ហ្នឹងមីងមកនៅភូមិហ្នឹងវិញហើយ?

យឿត: ៧៥ខ្ញុំនៅនេះឯង នៅក្នុងភូមិនេះឯង អត់មានជម្រៀសទៅណាទៀតទេ ធ្វើចំការ កាប់ថ្មល់ កាលនោះ៧៥អត់ទាន់មានថ្នល់ក្រហមទេ កាលសម័យកាលនោះអត់ទាន់មានទេ ធ្វើចំការ តាមជើងភ្នំនេះឯង ស្តុកអូញហ្នឹង អត់មានស្រឡះអញ្ចឹងទេ ។

វណ្ណៈ	ចុះ៧៥ចូលមកអ្នកដែលថាមានអាវខ្មៅយោធាអីគេមកអញ្ចឹង គេបង្កើតជាសហករណ៍អីដំបូងៗ គេអត់ទាន់បង្កើតឬក៏យ៉ាងម៉េច គេដឹកនាំយើងធ្វើការយ៉ាងម៉េច?

យឿត: គេដឹកនាំយើងធ្វើការ កាប់ចំការ គាស់គល់ដាំដំឡូងដាំអី ប៉ុន្តែខ្ញុំមិនសូវបាននៅភូមិទេ ខ្ញុំទៅ ចល័ត ។

វណ្ណៈ	ទៅចល័តតាំងពីឆ្នាំណាទៅ?

យឿត: ឆ្នាំដែលពួកខ្មែរក្រហមចូលមកនៅក្លាម អាពតចូលមកនៅភូមិនេះក្លាមខ្ញុំនេះគេរើសធ្វើនារីចល័តហ្នឹង ។

វណ្ណៈ	កាល៧៥ហ្នឹង?

យឿត: ចា៎! ចល័តទៅ ហើយខ្ញុំមិនបាននៅក្នុងភូមិនេះ ហើយមិនដឹងសាច់រឿងថាយ៉ាងម៉េចទេ ខ្ញុំចល័តហើយកាលអាពតចូលមកនោះ ។

វណ្ណៈ	ពីណាមកជ្រើសរើសមីង?

យឿត: ពួកគេហ្នឹងឯង គេចាប់យើងដាក់បញ្ចូលនារី ដូចថាយើងវារូបធំ ហើយអាយុវាតិច រូបយើងវាធំអញ្ចឹងចាប់ដាក់បញ្ចូលនារីទៅ ហើយក៏ទៅនឹងគេទៅ តែមិនដឹងឯណាឯណីផងបេះតែទៅៗ ។

វណ្ណៈ	នារីកងចល័ត?

យឿត: ចា៎! ចល័តនៅនេះ៣-៤ខែ ទៅនោះ៤-៥ខែទៅ បេះតែទៅៗ ។

វណ្ណៈ	កងចល័តស្រុកឬកងចល័តតំបន់?

យឿត: កងចល័តស្រុកព្រះនេត្រព្រះយើងនេះឯង មិនមែនតំបន់ទេ ។

វណ្ណៈ	កងចល័តស្រុកព្រះនេត្រព្រះហ្នឹងកាលហ្នឹងពីណាជាប្រធាន?

យឿត: ខ្ញុំអត់ចាំទេ ។

វណ្ណៈ	ចុះកាលចូលដំបូងហ្នឹង ដូចមីងទៅធ្វើការនៅម្តុំណា ទៅធ្វើស្រែឬក៏ទៅលើកភ្លឺ?

យឿត៖ ទៅលើកទំនប់ធំមុនដំបូងដែលខ្ញុំចាប់ផ្តើមទៅធ្វើការហ្នឹងលើកទំនប់អាផ្លូវទៅភ្នំស្រុកត្រពាំងថ្ម ហ្នឹងឯង ខ្ញុំទៅលើកនៅនោះឯង តែខ្ញុំនៅស្មើរដែរខ្ញុំអត់ចាំទេ បើដូចសព្វថ្ងៃនេះវិលហើយ តែខ្ញុំឡេឡឺអត់ចាំទេ ប៉ុន្តែខ្ញុំបានទៅលើកទំនប់ហើយ ហើយគេដាក់ទោសឲ្យយើងលើកម្នាក់ ២ម៉ែតគីបមុនដំបូង មិនទាន់ច្រើនទេ ម្នាក់២ម៉ែតគីបបើយើងលើកមិនរួចគេអត់ឲ្យបាយ យើងស៊ីឆ្អែតទេ គេបន្ថយរបបយើង គេមិនឲ្យពេញរបបទេ ។

វណ្ណៈ ហើយម៉េចទៀតទៅ?

យឿត៖ ដល់ពេលអញ្ចឹងយើងចេះតែខំលើកទៀតទៅ ខ្ញុំ២នាក់ចបមួយបង្គីរមួយសម្រាប់ រែកផ្លាស់គ្នាម្នាក់ម្តង ខ្ញុំខំណាស់ ខំឡើងបាក់កម្លាំងដល់សព្វថ្ងៃហ្នឹងខ្ញុំធំតែរូបទេ អត់មានកម្លាំងដូចពីដើមទេ ព្រោះបាក់កម្លាំង ចុះបើក្មេងទើបតែធំហ្នឹងទៅធ្វើការអញ្ចឹង ដូចពួងឯងដឹងស្រាប់ហើយ បានខ្ញុំខឹងអើយខឹង យី! អារលាយនេះវាប្រើយើងអត់មានមើលកម្លាំងថាក្មេងថាចាស់ទេ លើកទំនប់ពីនោះរួចទៅបានចេញពីនោះមកនៅនេះទៀត ដើរនៅនោះបន្តិចនេះបន្តិច ។

វណ្ណៈ តែខ្ញុំចង់ដឹងថា មីងដំបូងហ្នឹងគេថា ខ្លះគេថា៧៥ហ្នឹងត្រពាំងថ្មអត់ទាន់បង្កើតទំនប់ទេ ហើយគ្រាន់ទៅធ្វើការ ទៅសួងកន្លែងកងចល័តផ្សេងៗសិន ហើយក្រោយមកបានគេជ្រើសរើសទៅ ហើយមីងថាទៅតាំងពី៧៥?

យឿត៖ ខ្ញុំទៅតាំងពីមុនដំបូងបង្អស់ អាពត ចូលមកនៅនេះភ្លាមក៏គេរើសយើង យើងក៏ទៅភ្លាម ។

វណ្ណៈ ទៅអាងត្រពាំងថ្មភ្លាម?

យឿត៖ ទៅលើកទំនប់ កាលនោះសម័យអាពតគេហៅដើមពោធិ៍៣ដើម ផ្លូវទៅអាងត្រពាំងថ្មហ្នឹង ហើយខ្ញុំមិនដែលស្គាល់អាងត្រពាំងថ្មទេ ដឹងតែទំនប់ដើមពោធិ៍៣ដើម លើកថ្នល់ធំណាំខ្ញុំទៅ លើកអានោះឯងមុនគេបង្អស់ ។

វណ្ណៈ ហើយចេញពីហ្នឹងបានទៅត្រពាំងថ្ម?

យឿត៖ ត្រពាំងថ្មខ្ញុំអត់បានទៅទេ ខ្ញុំចេញពីនោះមកខ្ញុំទៅខាងនេះទៅរំដួល ទៅក្រឡាញ់នោះវិញ វាមុខក្រសួងខុសគ្នា ខ្ញុំខាងមួយផ្នែកមួយក្រុមម៉ាកងអញ្ចឹង កងគេខ្លះគេទៅខាងនោះ ខាងត្រពាំងថ្មមានក្រុមគេទៅផ្សេង ហើយខ្ញុំចេញពីដើមពោធិ៍៣ដើមផ្លូវភ្នំស្រុកហ្នឹងមក ខ្ញុំមកខាងព្រៃមាន់ខាងរំដួលភូមិក្រឡាញ់នេះ ឃុំភ្នំលាភ ខ្ញុំមកខាងនេះវិញគ្នាច្រើនណាស់មនុស្សរាប់រយរាប់ពាន់មិនដឹងណាណីទេអត់ស្គាល់គ្នាអស់ផងហ្នឹង បើនៅជុំគ្នាស្គាល់ ។

វណ្ណៈ ចុះកាលសម័យហ្នឹងមីងស្គាល់ដូចថាគណៈតំបន់ គណៈស្រុក គណៈភូមិភាគអីស្គាល់ទេកាលហ្នឹង ធ្លាប់ឮឈ្មោះទេ?

យឿតៈ ឮឈ្មោះ តែមិនដឹងអ្នកណាទេ នៅខ្វីដែរខ្ញុំអត់ស្គាល់ទេ។

វណ្ណៈ ឈ្មោះអីខ្លះ?

យឿតៈ ឮគណៈតំបន់ គណៈស្រុក ប្រធានក្រុម ប្រធានកង តែមិនដឹងមុខយ៉ាងណាទេព្រោះអត់ហ៊ានមើលមុខគេទេខ្លាច កាលនោះក្មេងដែរ។

វណ្ណៈ ឮឈ្មោះអីខ្លះទៅ?

យឿតៈ មិនចាំទេ។

វណ្ណៈ ចុះរស់ ញឹម ដែលឮទេ?

យឿតៈ អត់ទេ។

វណ្ណៈ ចុះ តាវ៉ាល់?

យឿតៈ តាវ៉ាល់ ឮតែឮតែឈ្មោះទេមិនដឹងមុខម៉េចទេ ខ្ញុំអត់ចាំទេព្រោះខ្ញុំមិនហ៊ានមើលមុខគេទេ។

វណ្ណៈ ចុះ តាជៀល?

យឿតៈ តាជៀល ក៏ឮ។

វណ្ណៈ ចុះ តាម៉ោង?

យឿតៈ តាម៉ោង ក៏ឮ ឮហៅថា នែ៎! ខ្លាចណាស់ក្រុមតាហ្នឹងកាចណាស់ ខ្ញុំឮតែខ្ញុំមិនបានឃើញមុខទេ ខ្ញុំមិនដែលឃើញទេ តែគ្រាន់ឮគេថាគាត់កាច។

វណ្ណៈ ចុះ តាក្រុក?

យឿតៈ តាក្រុក ក៏ដឹង បើតាក្រុក គាត់មកនេះឲ្យផ្ទាល់។

វណ្ណៈ តាក្រុក គាត់កាចទេ?

យឿតៈ មិនកាចណាស់ណាទេ។

វណ្ណៈ តែសម័យ តាក្រុក មានចាប់មនុស្សវៃចោលទេ?

យឿតៈ មាន។

វណ្ណៈ មនុស្សប្រភេទណាដែលគេយកវៃចោល?

យឿតៈ ប្រភេទអ្នកធ្វើការពីសង្គម គេអ្នកដូចថា តាភឹមព្រះនេត្រព្រះនោះ ប៉ុលសារ៉ែង កាលនោះឯងសម័យ តាក្រុក ហ្នឹងចាប់តាភឹម នោះឈ្មោះ តាភឹម នៅប៉ុលសារ៉ែងគាត់ឃុំព្រះនេត្រព្រះពីដើម កាលសម័យនោះគាត់ធ្វើឃុំ ដល់ពេលអាពតវាចូលមក តាក្រុក ហ្នឹង

ចូលមក ហើយតានោះគេចាប់យកទៅវៃចោលអស់ទៅ នៅសល់កូនមួយ ហើយរកចាប់គ្នាទៀតកាលហ្នឹង វៃជំនាន់ពួកខាងវាលនេះឯង កាលនោះខ្ញុំដឹង ។

វណ្ណៈ	តាក្រុក ចាប់ពីណា?

យឿតៈ	តាក្រុក ចាប់ កាលហ្នឹងពួកប៉ុលសាវ័ងជម្លៀសមកដល់នេះឯង មកដល់ភូមិស្រែះនេះឯង ដេញចាប់គ្នារត់ពួនដូចកូនមាន់ ។

វណ្ណៈ	ចាប់ពីណាគេ?

យឿតៈ	ចាប់កូនប្រធានឃុំឈ្មោះ តាភើម មេឃុំភើមពីដើម កាលពីសង្គមគេហៅគាត់ហ្នឹងមេឃុំភើម ដល់ពេលនេះគេយកឪទៅសម្លាប់ចោលអស់ នៅសល់កូនមួយ ។

វណ្ណៈ	ចុះម្ដាយគេសម្លាប់ដែរ?

យឿតៈ	ចាប់ទាំងអស់ ម៉ាពូជហ្នឹងងាប់ទាំងអស់នៅសល់តែមួយទេ សល់មីធន មួយហ្នឹងឯងម៉ាពោះហ្នឹង ។

វណ្ណៈ	មេឃុំហ្នឹងឈ្មោះ ភើម?

យឿតៈ	ចាំ! មេឃុំភើមកាលពីដើម គេហៅតែមេឃុំភើម កាលហ្នឹងខ្ញុំគ្រូគេហៅខ្ញុំស្គាល់ដែរគាត់នៅ នោះ គេហៅមេឃុំភើម ។

វណ្ណៈ	ចុះប្រពន្ធគាត់ឈ្មោះអី?

យឿតៈ	ប្រពន្ធគាត់ខ្ញុំអត់ស្គាល់ទេ ខ្ញុំស្គាល់តែគាត់ដែលគេតែងហៅ កាលហ្នឹងខ្ញុំស្គាល់គាត់តែប្រពន្ធគាត់ខ្ញុំមិនដឹងឈ្មោះអីទេ មិនស្គាល់គេ ព្រោះកាលហ្នឹងនៅតូចៗមិនសូវចាប់អារម្មណ៍ទេ ហើយតាភើមៗនេះខ្ញុំឮពុកខ្ញុំគាត់ហៅ កាលហ្នឹងគាត់ថា "ស្រណោះមេឃុំភើម ណាស់ គេចាប់យកទៅវៃចោល" ដល់ពេលនៅសល់កូនមួយនេះគេមកស្រាវជ្រាវចាប់ យកទៀត អ្នកណាកូនមេឃុំភើមនៅណា គ្នារត់ពួនដូចកូនមាន់ តែគេជួយលាក់ ។

វណ្ណៈ	ហើយរត់រួចទេ?

យឿតៈ	រត់រួច ព្រោះគេជួយលាក់ គេថាអត់មានទេអស់ហើយ គេស្លាប់ចោលអស់ហើយ គេថាអញ្ចឹងកាលសម័យហ្នឹង តាក្រុក គាត់មកនៅនេះឯង អាធំកូនតាភើមប្រុស ហើយដែលគេរកមួយទៀតនោះស្រី លាក់បានអត់ងាប់ទេ កាលហ្នឹងគេចខ្លួន គេនាំគ្នាថាអត់មានទេអស់ហើយ គេចាប់អស់ហើយគេថាអញ្ចឹង គេចេះតែជួយលាក់ ស្រណោះគ្នាកូនក្មេង បើម៉ែឪគេសម្លាប់ចោលអស់ហើយ ហើយគ្នានៅក្មេងអត់មានទុកគ្នានៅរកទៀត ។

វណ្ណៈ ចុះមីង នៅក្នុងភូមិឃុំរបស់មីង នៅក្នុងភូមិនេះជាពិសេសដូចថាអ្នក១៧មេសាអី មានមករស់នៅក្នុងហ្នឹងទេ?

យឿត: មាន មុននេះឯង កាលហ្នឹងឈ្មោះអីទេ ១៧មេសាហ្នឹងស្រីៗណា៎ ហើយសុទ្ធតែអាវខ្មៅ អញ្ចឹងមែន?

វណ្ណៈ មិនមែនទេ ។

យឿត: អញ្ចឹងម៉េចទៅ?

វណ្ណៈ ពួកប្រជាជនដែរ តែប្រជាជនភ្នំពេញ ពួកពីភ្នំពេញមក ពួកប្រជាជនភ្នំពេញគេជម្លៀសចេញពីភ្នំពេញមកឲ្យនៅក្នុងភូមិយើងហ្នឹងដែរ ក្នុងភូមិ តាមៗភូមិផ្សេងៗទៀត ដូចគេហៅអ្នកថ្មីៗ ?

យឿត: មានៗ ។

វណ្ណៈ ដូចថាអ្នកថ្មីៗដែលគេចង់យកវៃចោល?

យឿត: មាន ពួកអ្នកថ្មីមកឲ្យកំពេស ។

វណ្ណៈ ច្រើន?

យឿត: ចា៎! ច្រើន ។

វណ្ណៈ កំពេសហ្នឹងបានន័យថាច្រើន?

យឿត: ច្រើន ខ្ញុំចាំឈ្មោះមិនបានទេ មើលពួកបក្សខ្ញុំដែលចល័តជុំគ្នាឈ្មោះ អាខេង ឈ្មោះអាជី ឈ្មោះអាលៀង ស្រីៗចល័តជុំគ្នាពួកអ្នកថ្មី ដល់ហៅអញ្ចឹងបានខ្ញុំដឹង តែហៅនេះខ្ញុំអត់ដឹងទេ ។

វណ្ណៈ ហៅពួកអ្នកថ្មីដឹង?

យឿត: ចា៎!

វណ្ណៈ តែបើហៅពួកអ្នក១៧មេសាអត់ដឹងទេ?

យឿត: អត់ស្គាល់ទេ ខ្ញុំដឹងតែពួកអ្នកថ្មី គាត់មកគាត់ចល័តជុំគ្នា ។

វណ្ណៈ ហើយពួកហ្នឹងមានស្លាប់មានអីខ្លះទេ?

យឿត: មិនដឹងម៉េច ព្រោះបាត់ដំណឹងជ្រាប ពេលដែលនៅជុំគ្នាអត់មានស្លាប់ទេ ពេលចប់អាពតទៅក៏គេទៅស្រុកទៅស្រែវិញ គេទៅភ្នំពេញទៅអីវិញ ។

វណ្ណៈ ប៉ុន្តែពួកថ្មីមកហ្នឹង ហើយប្រជាជននៅក្នុងភូមិហ្នឹងម៉ាចំនួនមានគេយកទៅសម្លាប់ដែរឬក៏យ៉ាងម៉េច?

យឿត៖ ដូចអត់មានទេ មានតែដាច់ពោះ ។

វណ្ណៈ ដាច់ពោះស្លាប់?

យឿត៖ ចា៎!

វណ្ណៈ ស្លាប់នឹងអត់អាហារមែន?

យឿត៖ ចា៎! ស្លាប់នឹងអត់បាយ ។

វណ្ណៈ បើតាមមីងគិត អ្នកទៅកងចល័តស្រួលជាងអ្នកនៅក្នុងភូមិ ហើយអ្នកនៅក្នុងភូមិពិបាកជាង?

យឿត៖ អ្នកនៅកងចល័តស្រួលជាងអ្នកនៅក្នុងភូមិ ទោះបីអ្នកធ្វើការនឿយហត់យ៉ាងណាក៏បបរបាយមិនដាច់ទេ អ្នកនៅក្នុងភូមិគ្នាអត់ឡើងបាយត្រកួន ដើមចេក ខ្ញុំមកវិញពួកម៉ែខ្ញុំនិយាយប្រាប់អញ្ចឹង ហើយប្អូនខ្ញុំមីនេះនៅតូចៗហ្នឹង ។

វណ្ណៈ ចុះមីងអត់បានមកលេងទេ ពេលទៅចល័ត?

យឿត៖ ថាលួចមកម្តងៗ ពូអើយ! លួចមកអញ្ចឹងបានមួយថ្ងៃពីរថ្ងៃប្រធានភូមិគេដឹងគេថាយើងមកអត់មានរបបទេ គេដេញយើងទៅវិញ ម៉ែខ្ញុំយំដោយសារតែកូននេះឯង តែកូនមកគេអត់ឲ្យរបបយើងទេ គេដឹងគេតាមយកទៅវិញ ។

វណ្ណៈ មកឃើញគាត់ហូបបបរមែន?

យឿត៖ ចា៎! ឲ្យតែនិយាយរឿងហ្នឹងខ្ញុំចង់តែយំ ព្រោះវាឆ្អែតពេក ។

វណ្ណៈ អញ្ចឹងខ្ញុំសួរមីងដឹងទៅ ដំបូងដូចថាមីងទៅ៧៥ហ្នឹងមីងចេញពីផ្ទះប្រហែលជាខែអីគេ ខែប្រាំងឬក៏ខែវស្សា ឬក៏ខែណាដែលមីងចេញទៅដំបូង?

យឿត៖ ចេញទៅខែប្រាំង មើលតែគេយកអាគ្រាក់មកហ្នឹង ខ្ញុំឡើងអាគ្រាក់មិនរួចផង ទាល់តែគេដឹកដៃ ហើយគេលើកដាក់ ។

វណ្ណៈ គេយកអាគ្រាក់មកដឹក មិនមែនយើងដើរទៅទេ?

យឿត៖ យកអាគ្រាក់មកដឹក តែនិយាយរឿងហ្នឹងខ្ញុំចង់តែយំទេ ឈឺចាប់ណាស់ វាកំសត់ពេកនិយាយប្រាប់ពួកកូនៗខ្ញុំវាថាម៉ែឯងយ៉ាប់កន្លែងណា យ៉ាប់ណាស់កូនទម្រាំបានមានជីវិតរស់មកដល់សព្វថ្ងៃនេះ ។

វណ្ណៈ ក្មេងៗបើសិនជាយើងអត់ធ្វើការចងក្រងស្រាវជ្រាវទុកជាឯកសារទេ ច្បាស់ជានិយាយមាត់ទទេអត់ជឿទេ ។

យឿត៖ អត់ជឿទេ គេតែងយកកុនមកបញ្ចាំងមើលតាមភូមិនេះកូនខ្ញុំទៅមើល ខ្ញុំថាដែលឃើញហ្នឹងសុទ្ធតែរឿងពិត មិនមែនក្លែងក្លាយទេ។

វណ្ណៈ អញ្ចឹងធ្លាប់គេមកបញ្ចាំងកុនឲ្យមើលដែរ?

យឿត៖ មក គេមកបញ្ចាំង ហើយខ្ញុំដេញឲ្យកូនខ្ញុំទៅមើល ខ្ញុំថាកូន រឿងហ្នឹងសុទ្ធតែរឿងពិតមិនមែនរឿងក្លែងក្លាយទេ។

វណ្ណៈ បញ្ចាំងនៅណា?

យឿត៖ បញ្ចាំងក្នុងភូមិយើងនេះឯង នៅសាលារៀន។

វណ្ណៈ បញ្ចាំងរឿងខ្មែរក្រហម?

យឿត៖ បញ្ចាំងរឿងអាពតចូលមកវាវ៉ៃយើង វាធ្វើបាបយើង វាវ៉ៃចោល ហើយគ្រាន់តែលួចដំឡូងមួយដុំក៏វាយកយើងទៅវ៉ៃចោលដែរ ពួកអ្នកដែលមកពីភ្នំពេញ ដូចថាវាតាមដានច្បាស់ដូចថា ធ្វើការដូចលោកពូមកធ្វើការនៅក្នុងភូមិខ្ញុំអញ្ចឹងណា៎ ឲ្យតែវាតាមដានច្បាស់វាចាប់ហើយ ប៉ុន្តែពួកយើងដែលចាស់ហ្នឹងចេះតែលាក់ណា៎ ថាមិនមានទេ ប៉ុន្តែពួកនោះមកអត់មានធ្វើខ្លួនទេ មកហ្នឹងខោមិនខោ អាវមិនអាវ គាត់ដើរធ្វើឡឺៗហ្នឹង ប៉ុន្តែគាត់ចេះណា៎ បើយើងអ្នកចាស់នេះឈឺអីមិនស្រួលអញ្ចឹងគាត់លួចយកមកថ្នាំមកឲ្យ យកមកឲ្យលេបគាត់ចេះណាស់។

វណ្ណៈ ប៉ុន្តែអ្នកស្រុកអ្នកភូមិខ្លះអាណិតជួយលាក់ដែរ?

យឿត៖ ជួយលាក់ អត់បញ្ចេញទេ ជួយលាក់ ព្រោះគាត់មកសុទ្ធតែពួកអ្នកថ្មី គាត់មានណា៎ សាច់ឈាមគេស្អាតៗណា៎ ហើយគេមានថ្នាំជាប់យកមកផង ពេលយើងគ្រុនរងាគេជួយ បើសិនជាគេមិនជួយទេក៏យើងអាចសូកប៉ាន់គ្នា មានអង្ករក៏ចែកគ្នាទៅ ២-៣កំប៉ុងទៅ ហើយគេក៏យកថ្នាំមកឲ្យយើងទៅ វាអញ្ចឹងឯងវាមិនដែលអត់ទេ លួចបូតស្រូវ បើមិនអញ្ចឹងម៉េចបានអង្ករបបរស៊ី ហើយពួកអ្នកថ្មីគ្នាអត់ទៅមកមានខោអាវ មានថ្នាំយកមកទៅ ក៏ឲ្យប្រជាជនមូលដ្ឋានណា៎ ថាអ៊ំអើយ អ៊ំឯងមានអង្ករច្រើនឲ្យកូនសុំ២-៣កំប៉ុងមកយក ទៅលាយ ហើយខ្ញុំមានថ្នាំឲ្យអ៊ំឯងអញ្ចឹងទៅ ដដែកគ្នាទៅនោះគេយកថ្នាំបាត់គ្រុនបាត់អី ទៅ តែគេឃើញមិនបានទេមើលខ្ញុំនេះស្នាមនៅសព្វថ្ងៃនេះ ច្រូតស្បូវ ដាក់ទោសឲ្យច្រូត ស្បូវម៉ាថ្ងៃ២បាច់ប៉ុនៗនេះរួចក្រងមួយថ្ងៃ២០កណ្ដាប់ ខំទៅច្រូតដណ្ដើមគ្នាច្រូត ដល់ ហើយក៏មុតដៃនឹងកណ្ដៀវខានធ្វើការ៨-១០ថ្ងៃទម្រាំសាសន៍ ក៏បានអ្នកថ្មីនេះឲ្យ៥សេន

ម៉ាចំហៀងគ្រាប់ចេះលាបបាត់ បើដូចយើងសព្វថ្ងៃប្រឡេះចាក់អស់មិនចេះតិចម្ភៃ ៥សេនម៉ាចំហៀងគ្រាប់ចេះលាបបាត់។

វណ្ណៈ អញ្ចឹងលាបទៅ?

យឿតៈ ចា៎! កំសត់ណាស់ ឲ្យតែនិយាយខ្ញុំចង់តែយំ។

វណ្ណៈ ចុះមីងដូចថាចេញទៅធ្វើការកងចល័តស្រុក ចេញទៅដំបូងនៅទីតាំងកន្លែងណា៎ មីងជួយប្រាប់ខ្ញុំម្តងទៀតបានទេ?

យឿតៈ មុនដំបូងខ្ញុំនៅដើមពោធិ៍៣ដើមហ្នឹងឯង ផ្លូវទៅភ្នំស្រុក។

វណ្ណៈ ដើមពោធិ៍៣ដើម?

យឿតៈ ចា៎!

វណ្ណៈ ហ្នឹងទំនប់ដែរ?

យឿតៈ ចា៎! ទំនប់ដែរ ដល់ចេញពីនោះមកខ្ញុំនៅអារ៉ាក់បាក់ក ផ្លូវទៅស្វាយនេះ ខាងលិចឈ្នួល។

វណ្ណៈ ឥឡូវខ្ញុំចង់សួរដើមពោធិ៍៣ដើមសិន?

យឿតៈ ចា៎! ដើមពោធិ៍៣ដើមហ្នឹង តែខ្ញុំអត់បាននៅយូទេ នៅបានតែមួយខែទេគេដកចេញមកទៀតហើយគេផ្លាស់។

វណ្ណៈ នៅដើមពោធិ៍៣ដើមហ្នឹងគេវាស់ដីយ៉ាងម៉េចមីង?

យឿតៈ គេវាស់ដីម្នាក់២ម៉ែត្រគីបក្នុងមួយថ្ងៃឲ្យយើងលើកណា៎ ហើយយើងលើកមិនរួចគេឲ្យយើងលើកទាល់តែរួច បើថ្ងៃលើកមិនរួចយប់យើងលើកទៀត ម៉ោង៨-៩បានយើងមកដេក។

វណ្ណៈ អញ្ចឹងបើយើងលើកមិនរួចយើងត្រូវតែខំលើក?

យឿតៈ ចា៎! ខំលើកទាល់តែរួច ចុះភ័យបើយើងលើកមិនរួចគេយកទៅវៃចោលយើងមិនខ្លាច។

វណ្ណៈ ទំនប់ហ្នឹងធំទេ?

យឿតៈ ធំណាស់ ដូចថ្នល់យើងព្រះនេត្រព្រះអញ្ចឹងឯង ដូចថ្នល់ដែលយើងមកអញ្ចេះ។

វណ្ណៈ ហើយប្រវែងឆ្ងាយទេ?

យឿតៈ ឆ្ងាយ គេលើកពីថ្នល់ជាតិនេះទៅខាងកើតមិនដឹងទៅដល់ណាទេ ខ្ញុំមិនដឹងទេ មិនដឹងជាប៉ុន្មាន ម៉ែត្រទេ ហើយមានគេអ្នកដើរវាស់ គេអ្នកដើរតម្រង់ខ្ញុំមិនដឹងទេ ហើយនៅទីជងខ្លាចគេ សូម្បីតែគេឲ្យខ្ញុំនៅកន្លែងចាំខ្ទមយប់ក៏ខ្ញុំមិនហ៊ាននៅទេ ខ្ញុំខ្លាច ខ្លាចខ្មោចអត់ហ៊ាននៅទេ។

វណ្ណៈ អញ្ចឹងកាលហ្នឹងដូចថាយើងហូបបាយដែរ?

យឿត៖ ចា៎! មុនដំបូងហូបបាយអត់ទាន់បបរទេ ដល់ពេលជិតចប់ហើយបានវាមិនឲ្យយើងស៊ីបាយទេ ។

វណ្ណៈ អញ្ចឹងនៅកន្លែងហ្នឹងមានខ្វះទឹកខ្វះអីទេ?

យឿត៖ អត់ខ្វះទេ មុនដំបូងដែលខ្ញុំនៅអត់ខ្វះទេ ដល់គេមកនៅក្រោយទៀតបានខ្វះ ខ្ញុំទៅនៅនោះ ២-៣ខែ នៅនោះ២-៣ខែ នៅនេះនៅនោះ អត់មាននៅមួយកន្លែងទេ ចល័តពេញណាពេញណី ។

វណ្ណៈ ពេលព្រឹកម៉ោងប៉ុន្មានធ្វើការ?

យឿត៖ ម៉ោង៧ចាប់ផ្តើមចេញទៅធ្វើការហើយ ។

វណ្ណៈ ម៉ោងប៉ុន្មានសម្រាកហូបបាយ?

យឿត៖ ម៉ោង១១គេឲ្យឡើងមកស៊ីបាយ ។

វណ្ណៈ ចុះពេលថ្ងៃ?

យឿត៖ ពេលថ្ងៃម៉ោង១ចុះទៅធ្វើការទៀត ។

វណ្ណៈ ដល់ម៉ោង៥យើងសម្រាក?

យឿត៖ ចា៎!

វណ្ណៈ តែបើយើងអត់ហើយអត់បានសម្រាកទេ?

យឿត៖ អត់បានទេ បើសិនជាយើងចង់លឿនយើងក្រោកតាំងពីម៉ោង៤ព្រឹក អត់ទាន់ភ្លឺណាក្រោកទៅរែកដី ។

វណ្ណៈ អញ្ចឹងគេវាស់ទុកឲ្យដូចថាពេលល្ងាចហើយអញ្ចឹងគេវាស់ទុកឲ្យយើងទៀត?

យឿត៖ ចា៎! ធ្វើការអត់មានដាក់ថ្ងៃទេកាលនោះ សម្រេចតែម៉ារួច គេដាក់តែម៉ែត្រគីបឯង គេអត់ មានកំណត់ម៉ោងឲ្យយើងទេ យើងធ្វើយ៉ាងណាធ្វើទៅឲ្យតែរួច ។

វណ្ណៈ ចុះនៅដើមពោធិ៍៣ដើម មីងគិតមើល មនុស្សរាប់ម៉ឺនរាប់ពាន់នាក់ឬក៏ប៉ុន្មាននាក់?

យឿត៖ ច្រើនណាស់អូនអើយ មិនដឹងប៉ុន្មានទេឡើងកំពេស ច្រើនណាស់និយាយទៅច្រើនណាស់ ថាកំពេសចុះ វារត់មាត់តែកំពេសនេះឯង ច្រើនណាស់ទាំងស្រីទាំងប្រុសមិនដឹងណាណីទេ ។

វណ្ណៈ នៅស្រុកហ្នឹងគេធ្លាប់និយាយអញ្ចឹង?

យឿត៖ ចា៎! អាច្រើនក៏ដឹង អាកំពេសក៏ដឹង និយាយបានទាំងអស់ ។

វណ្ណៈ ចុះនៅកន្លែងដើមពោធិ៍៣ដើម តាវ៉ាល់ មានទៅបញ្ញាប្តូទៅប្រជុំយ៉ាងម៉េចទេ?

យឿត៖ គាវ៉ាល់ ទៅប្រជុំហ្នឹងឯង ទៅប្រជុំដែលយើងប្រជាជនតូចៗហ្នឹងមិនដឹងទេ មិនដឹងគេថាអី ទេ គេប្រជុំប្រធានកងធំៗ គេហៅទៅប្រជុំ ដូចថាការងារសម្ងាត់ៗអញ្ចឹងគេមិនដែលឲ្យ យើងដឹងទេ គេហៅតែប្រធានៗទៅប្រជុំ យើងប្រជាជនមិនដឹងអីទេ តែប្រធានក្រុម ។

វណ្ណៈ ចុះប្រធានក្រុមគ្រប់គ្រងមីងហ្នឹងពីណាគេ?

យឿត៖ មិនដឹងឈ្មោះអីទេ ខ្ញុំអត់ចាំទេ ។

វណ្ណៈ មីងអត់មានបានគ្រប់គ្រងអីគេ?

យឿត៖ អត់ទេ អត់មានបានធ្វើអីទេ ។

វណ្ណៈ អត់មានបានធ្វើប្រធានក្រុមទេ?

យឿត៖ អ៎! មិនចេះទេ គឺថាតូចៗជាងគេ គេថាឯងតូចជាងគេកុំទៅធ្វើការយប់អី នៅចាំកន្លែងទៅ ហើយកាលហ្នឹងខ្ញុំខ្លាចខ្មោចណាស់ ។

វណ្ណៈ ហើយទៅធ្វើការហ្នឹងគេដែរ?

យឿត៖ ទៅដែរមិននៅទេ សូម្បីតែគេឲ្យខ្ញុំសម្រាកដាំបាយដូាស់គ្នាដាំបាយក៏ខ្ញុំមិនចេះដាំបាយដែរ ឆ្នាំងប៉ុណ្ណណឹអាណាទៅដាំឆ្អិន ខ្ញុំមិនដែលដាំបាយទេ មានតែប្រធានចាស់ៗដែលគាត់ចាស់ ជាងយើងគាត់នៅដាំបាយ ហើយខ្ញុំនៅក្មេងៗខ្ញុំមិនដឹងដាំបាយបានឆ្អិនទេ អាយុ១២-១៣ ឆ្នាំហ្នឹងប៉ុនកូនខ្ញុំមីនេះឯង ។

វណ្ណៈ ចុះចេញពីដើមពោធិ៍៣ដើមទៅណាទៀត?

យឿត៖ មុនដំបូងចេញពីដើមពោធិ៍៣ដើមគេបញ្ជូនមកស្រុកព្រះនេត្រព្រះនេះវិញ ដល់រួចទៅគេយក ទៅនៅកន្លែងអាវ៉ាក់បាក់កខាងលិចឈ្នួល ដល់ពេលនៅនោះបានមួយខែពីរខែ គេថាអ៎! ឥឡូវគេទាក់ទងចល័តឲ្យទៅខាងកើត ទៅឃុំភ្នំលាភ ទៅស្ទូង គេដកយកទៅនោះទៀត ។

វណ្ណៈ មកស្រុកព្រះនេត្រព្រះបានប៉ុន្មានខែដែរ?

យឿត៖ មកមិនបាននេះទេ មកបានប្រហែលជាមួយខែឯងដកទៅវិញហើយ ដកទៅនៅឃុំ ភ្នំលាភ ។

វណ្ណៈ មួយខែនៅព្រះនេត្រព្រះហ្នឹងគេឲ្យធ្វើអី?

យឿត៖ ខាងស្ទូង ខ្ញុំឈប់លើកទំនប់ហើយ ខ្ញុំស្ទូងម្តង ស្ទូងឡើងសឹកដៃអស់ហើយ ។

វណ្ណៈ ហើយចេញពីព្រះនេត្រព្រះទៅណាទៀត?

យឿត៖ ទៅឃុំភ្នំលាភ ឃុំភ្នំលាភនោះទៅចល័តហ្នឹង ប៉ះទំនប់លើកទំនប់ ប៉ះស្ទូងក៏ស្ទូង ។

វណ្ណៈ ភ្នំលាភ?

យឿតៈ ចា៎!

វណ្ណៈ លើកទំនប់ហើយនឹងស្ទូង?

យឿតៈ លើកទំនប់ផង ស្ទូងផង ដល់ពេលច្រូតនៅឡើងយូ ច្រូតផង បោកស្រូវផង ថ្នាក់យប់ អញ្ចឹងទៅអង្គុយចងស្រូវបោក ។

វណ្ណៈ អញ្ចឹងរាប់ឆ្នាំនៅហ្នឹង?

យឿតៈ នៅនោះបាន៦ខែ ទៅនៅភ្នំលាភបាន៦ខែ ។

វណ្ណៈ កាលទៅនៅភ្នំលាភហ្នឹងក្រុមនារតីមកនូវ ដូច យាយថែម អីមកនូវ?

យឿតៈ មកហើយ យាយថែម យាយចាំង អីមកហើយពួកឈ្មោះ ។

វណ្ណៈ មិនទៅធ្វើស្រែនៅភ្នំលាភហ្នឹង?

យឿតៈ ចា៎! ចល័ត ។

វណ្ណៈ ចល័តហ្នឹង?

យឿតៈ ចា៎!

វណ្ណៈ អញ្ចឹង៧៨ហ្នឹង?

យឿតៈ មិនដឹង៧០ប៉ុន្មានទេ ខ្ញុំមិនបានដឹងទេមិនដឹង៧០ប៉ុន្មានទេ នៅខ្ទីណាស់អត់ទាន់ដឹងទេ ពួកគេថា យាយថែមៗ ហើយក៏យាយថែម ហ្នឹងគេទៅ ហៅនឹងគេទៅ ។

វណ្ណៈ ចុះពេលក្រុមនារតីមក ដូច យាយថែម អីហ្នឹងមកអញ្ចឹង មីងដឹងថាមានចាប់មនុស្សមួយចំនួនសម្លាប់ទេ មីងមានដឹងទេ?

យឿតៈ ទេ ខ្ញុំដូចជាមិនដឹងទេ ដូចជាមិនឃើញទេ ។

វណ្ណៈ ចុះពួក តាម៉ោង តាជៀល តាវ៉ាល់អីទៅណាអស់ទៅពេលហ្នឹង?

យឿតៈ បើពួកតាៗនោះមាន បើថាពួកនារតីដែលមកក្រោយអត់មានទេ ដូចជាមិនមានចាប់ទេ ។

វណ្ណៈ ចុះពួកនារតីមកចាប់តាវ៉ាល់ តាម៉ោង អីអស់ទៅមីងអត់មានដឹងទេ?

យឿតៈ អត់ដឹងទេ ។

វណ្ណៈ ចាំមើល! កាលជំនាន់ តាម៉ោង តាវ៉ាល់ តាជៀល អីហ្នឹងគាត់ធ្វើការនៅក្នុងស្រុកព្រះនេត្រព្រះអីហ្នឹង គាត់ចាប់ប្រជាជនមួយចំនួនដូចថាជា យោធា ជាប់ធ្វើការឲ្យលន់នល់ អញ្ចឹងគេសម្លាប់ចោល ដល់ពេលពួននារតីមកចាប់ពួកហ្នឹងទាំងអស់ ។

យឿត: ចាប់តទៀត ខ្ញុំដឹងតែពួកនារតីមក ដល់ពេលនេះបាត់អាឈ្មោះតាៗហ្នឹងអស់ទៅ កាលមុនដំបូងពួឈ្មោះតាៗហ្នឹង អត់ដឹងថាគេចាប់ទៅណាទេ ខ្ញុំអត់ដឹងទេព្រោះវានៅក្មេងដែរ ដល់ពេលតាៗហ្នឹងមុនដំបូងតាៗនោះឯង ដល់ពេលនារតីចូលមកនេះវាបាត់តាៗនោះអស់ទៅ មិនដឹងគេផ្លាស់ទៅណាអស់ ។

វណ្ណៈ: តាក្រុក ហ្នឹងគេចាប់ធ្វើស៊ីអស់ហើយ ។

យឿត: ចា៎! គេចាប់អស់ហើយ តែខ្ញុំអត់ដឹងទេ តាៗទាំងនោះដល់ពេលពួននារតីចូលមកតាៗទាំងនោះគេផ្លាស់ទៅខាងណា អត់មានដឹងថាគេចាប់ទៅណាទេ ខ្ញុំដឹងតែផ្លាស់ សូម្បីតែនារតីទៅវិញក៏ដោយក៏ខ្ញុំអត់ដឹងថាគេទៅវិញទេ គេប្រាប់យើងថា “មិត្តឯងកុំទៅណា នៅមើលចានឆ្នាំង ផ្ទះអី គ្រែក្រោញអី ចានបារាំងចានអីនៅមើលទាំងអស់ អត់មានឲ្យអ្នកណាយកទេ” មិត្តឯងកុំយកទៅណា ខ្ញុំទៅប្រជុំតែប៉ុន្មានម៉ោងទេ តែ២ម៉ោង៣ម៉ោងមកវិញហើយ ។

វណ្ណៈ: មីងម៉េចបានគេឲ្យនៅមើលចានឆ្នាំង មីងចុងភៅ?

យឿត: មិនមែនចុងភៅទេ តែគេផ្តាំផ្ញើរមុននឹងគេចេញទៅ យើងមកហូបបាយកំពុងតែហូបបាយគេ ហៅយើងទៅ ហើយរៀបឥវ៉ាន់ស៊ីៗទៅ ។

វណ្ណៈ: អាហ្នឹងជិតយួនចូលមកហ្នឹង?

យឿត: ចា៎! ជិតយួនចូលមក ។

វណ្ណៈ: គេប្រាប់ថាម៉េច?

យឿត: គេផ្តាំផ្ញើរនឹងយើងហ្នឹងថា កុំឲ្យយកចានឆ្នាំងទៅណា ខ្ញុំទៅប្រជុំតែ២-៣ម៉ោងទេមកវិញហើយ ។

វណ្ណៈ: តែតាមពិតរត់សោះ?

យឿត: ខ្ញុំអត់ដឹងទេ គិតទៅពួឯងមើលកូនក្មេងឆោតមែន ខ្ញុំថាបើសិនជាខ្ញុំចាស់ដូចសព្វថ្ងៃខ្ញុំមិនមែន ឆោតអញ្ចឹងទេ ខ្ញុំឆោតណាស់ ចានបារាំង កន្ទេល ខ្នើយ គ្រែអីឡើងកំពេសខ្ញុំអត់ហ៊ាន យករបស់គេទេ ខ្ញុំខ្លាចម្ចាស់គេមកវិញ ខ្ញុំអត់ហ៊ានទេ ក៏នាំគ្នាពិគ្រោះគ្នាយើង យើងទំបុក ស្រូវបុកអង្ករទុកទៅ តែគេមកវិញយើងលាក់អង្ករទុកបានដាំបាយស៊ី ស្រាប់ទម្រាំតែដឹង ពួកគេអ្នកដឹងគេប្រមូលចានឆ្នាំងអស់រលីង គ្រែក្រោញអីគេដឹកអស់អាលីង ហើយខ្ញុំថាអី! ម៉េចយករបស់គេ ប្រយ័ត្នម្ចាស់គេមកវិញ ហើយគេថាអត់មកទេ វាទៅងាប់អស់ហើយ យួនចូលមកហើយ រំដោះបានហើយ ដល់ហើយបានខ្ញុំដឹង មុនហ្នឹងខ្ញុំអត់បានដឹងទេ ដល់

ហើយបានថាអ៎! លួងមែន ក្មេងល្ងង់អត់មានដឹងអីទេ ទើបតែចាស់ក្រេវក្រោធមកបរទេស ហ្នឹងមកហ្នឹងបានដឹង និយាយពីខ្លាច សូម្បីតែចានបាយរាំងមួយក៏មិនហ៊ានយករបស់គេដែរ ខ្លាចគេមកវិញធ្វើបាបយើង ។

វណ្ណៈ ចុះមីងធ្វើការនៅភ្នំលាភហ្នឹងធ្វើរយៈពេលប៉ុន្មានខែ ៦ខែហើយមីងទៅណាទៀត មីងទៅធ្វើការនៅណាទៀត?

យឿតៈ ដល់ពេលបាន៦ខែទៅ មកពីនោះមកនៅនេះឯង មកនៅស្រម៉ោចនេះ ។

វណ្ណៈ មកនៅស្រម៉ោចនេះធ្វើអី?

យឿតៈ នៅស្រម៉ោចដែលខ្ញុំថាច្រូតហ្នឹងឯង ខ្ញុំផ្លាស់ពីនោះមកវិញហើយ មកស្រម៉ោចនេះហើយ នៅស្រម៉ោចជិតភូមិស្រែះនេះឯង នៅស្រម៉ោចហ្នឹងច្រូត ដល់ពេលច្រូតៗទៅបាន ដល់ពេលគេឡើងស៊ីបាយបានពួកនារីគេចេញទៅគេផ្ដាំផ្ញើរឿងចានឆ្នាំងហ្នឹងឯង ថាកុំឲ្យយករបស់គេទៅ ។

វណ្ណៈ អាហ្នឹងគេហៅភូមិស្រម៉ោច?

យឿតៈ ចា៎! ភូមិស្រម៉ោចខាងលិចស្រែះនេះឯង ដល់ពេលចប់ខ្ញុំមកចប់នៅភូមិស្រម៉ោចនេះឯង ខ្ញុំអត់មាននៅឆ្ងាយទេ មុនដំបូងខ្ញុំដើរឆ្ងាយៗ អាគាត់អាតែងទៅនេះទៅនោះ ទៅណាទៅណីទេ ហើយនៅក្មេងអត់មានបានស្គាល់អ្នកណាអ្នកណីទេ ។

វណ្ណៈ កាលជំនាន់ហ្នឹងធ្វើស្រែមែន?

យឿតៈ ធ្វើស្រែ ឈប់លើកទំនប់ហើយ ខ្ញុំលើកទំនប់តែដំបូងទេ ។

វណ្ណៈ ដកស្ទូងនៅហ្នឹងហូបចុកយ៉ាងម៉េចដែរ?

យឿតៈ ហូបចុកធម្មតា ហូបបាយម៉ាផ្អែតៗ ទៅស្ទូងស្រូវដូចច្រូតស្រូវអីណា៎ ។

វណ្ណៈ អញ្ចឹងពេលរត់មកផ្ទះអី តើគេតាមចាប់តាមអីទេ?

យឿតៈ បើខ្ញុំនៅជិតគេអត់តាមទេ បើខ្ញុំនៅឃុំភ្នំលាភគេតាមចាប់ ខ្ញុំលួចរត់មកនៅក្នុងភូមិគេស៊ើបដឹងថាយើងចល័តរត់មក ។

វណ្ណៈ រយៈពេល៣ឆ្នាំហ្នឹងមីងរត់មកលេងផ្ទះបានប៉ុន្មានដង?

យឿតៈ ខ្ញុំរត់មកបាន២-៣ដងដែរ ដល់ហើយគេចាប់យកទៅវិញ ដល់ពេលទៅវិញគេថា ម៉ែខ្ញុំយំអើយយំ ម៉ែគាត់ថាកូនអើយ កូនឯងខំរត់មកលាក់ខ្លួនបាន៤-៥ថ្ងៃគេឲ្យទៅវិញទៀតហើយ កូនធ្វើម៉េចតស៊ូទៅ ខ្ញុំរករត់ទៅខាងតំបន់៣ តែម៉ែខ្ញុំអត់ឲ្យទៅទេ ខ្ញុំថាតំបន់៣ហ្នឹងសំបូរស៊ីតើ មិនមែនដូចតំបន់៩យើងទេ កាលហ្នឹងគេហៅតំបន់៩នៅនេះណា៎ ដល់ពេល

ស្មឹងខាងត្បូងនោះគេហៅតំបន់៣ ដល់ពេលខ្ញុំរករត់ទៅខាងតំបន់៣គេសំបូរស៊ី ខ្ញុំរករត់ទៅ តែម៉ែខ្ញុំអត់ឲ្យទៅ ដល់ហើយពិគ្រោះគ្នា ដល់ពេលប្រធានភូមិយើងនេះប្រធានឃុំយើងនេះ ឯង ឈ្មោះអីទេ ដូចជាអាប៉ិ ប៉ិន ប៉ុក៏ គ្រឿប ទេគេតាមដានថាខ្ញុំហ្នឹងចង់រត់ គេហៅខ្ញុំទៅ កសាង ថាមិត្តឯងគោលជំហរអត់រឹង មិត្តឯងឃើញខាងតំបន់គេមានស៊ីមានអីគ្រប់គ្រាន់ មិត្តឯងចង់រត់ចូល ហើយខ្ញុំថាខ្ញុំមិនបានរត់ទេបង ខ្ញុំសុំម៉ែមិនបានឲ្យទៅទេ ម៉ែខ្ញុំគាត់ថានៅ នេះហើយកូនអើយ ទោះអត់ស៊ីឃ្លានក៏ជុំម៉ែជុំឪ ទោះរាប់រស់យ៉ាងណាក៏បានជុំម៉ែជុំកូន ដែរ ។

វណ្ណៈ ប្រាប់ប្រធានភូមិអញ្ចឹង?

យឿតៈ ចា៎! បងឯងមិនបាច់ភ័យទេ មិនបានទៅទេ បើខ្ញុំទៅខ្ញុំទៅបាត់ហើយមិនមែនឲ្យបងឯងដឹង ទេ ។

វណ្ណៈ ថាអញ្ចឹង?

យឿតៈ ចា៎! តាមពិតគេអត់យកទោសព័យអីទេ គេថាល្អមិត្តឯងគោលជំហររឹង នេះបើសិនជាមិត្ត ឯងគោលជំហរទន់ប្រលែងចោលបាត់ហើយ ។

វណ្ណៈ គេថាអញ្ចឹងឲ្យយើងវិញ?

យឿតៈ គេសរសើរយើងថាយើងគោលជំហររឹងមិនទៅ បើសិនជាគោលជំហរទន់ម្ល៉េះទៅបាត់ហើយ ទៅចោលម៉ែចោលឪ ។

វណ្ណៈ ចុះកាលហ្នឹងដូចថាមានអ្នកថ្មីៗរត់ទៅខាងតំបន់៣ទេ ដូចថាអ្នកប្រជាជនថ្មីហ្នឹង?

យឿតៈ ដែលមកនៅនេះអត់មានរត់ទេ មកនៅជុំគ្នាទាំងអស់ ។

វណ្ណៈ ចុះមីងនៅហ្នឹងម៉េចដឹងថាខាងតំបន់៣គេហូបចុកស្រួលបួល?

យឿតៈ គេប្រាប់ ។

វណ្ណៈ ពីណាប្រាប់?

យឿតៈ ពួកអ្នកខាងនោះឯង ជួបគ្នាទៅគេប្រាប់ លួចចេញឆ្លងស្ទឹងទៅជួបគ្នាណា៎ ។

វណ្ណៈ អ៎! ឆ្លងស្ទឹង?

យឿតៈ ចា៎! ឆ្លងស្ទឹងមក យើងអុំទូកអញ្ចឹងទៅជួបគ្នា ដល់ទៅគេប្រាប់ថានែ៎ នៅខាងតំបន់នាង យ៉ាប់ណាស់ រត់មកខាងនេះមក ខាងនេះគេស៊ីគ្រប់គ្រាន់ ចុះបងប្អូនមីងមាខ្ញុំគេនៅខាងនោះ ដែរ

ហើយយើងចង់ទៅពុកម៉ែយើងនៅខាងនេះគាត់មិនឲ្យទៅ គាត់ថាបើងាប់ឲ្យបានជុំម៉ែជុំឪកូនឯងកុំទៅអី កូនឯងទៅខ្ចាចបែកគ្នា ។

វណ្ណៈ គាមនៅតំបន់៣ហ្នឹងមែនតើ ខ្ញុំសួរប្រជាជនថានៅហ្នឹងស្រួលមែន ហើយអ្នកកាន់នៅតំបន់៣ ហ្នឹងតាហ្នឹងឈ្មោះតា ញឹក លី ។ ញឹក លី ហ្នឹងខ្ញុំទៅជួបគាត់ហើយគាត់កាន់គណៈឃុំហ្នឹង គាត់និយាយថាកន្លែងគាត់មុនដំបូងខ្ញុំស្មានតែគាត់និយាយអួត គាត់និយាយថា ចុំជំនាន់ខ្មែរក្រហមកន្លែងណាក៏ហូបចុកវេទនាដែរ ហើយម៉េចក៏គាត់ថាឲ្យប្រជាជនហូបគ្រប់គ្រាន់ មិនដែលយកទៅសម្លាប់ ។

យឿតៈ មិនសម្លាប់ហើយឲ្យគេស៊ីឆ្អែតទៀត ។

វណ្ណៈ ដល់ពេលហើយខ្ញុំចេះតែស្តាប់គាត់សិនណា៎ ដល់ពេលខ្ញុំទៅសួរប្រជាជន ប្រជាជនថាពុកលីហ្នឹងពីណាក៏សរសើរគាត់ដែរ គាត់អត់មានឲ្យប្រជាជនហូបអត់ឃ្លានទេ គាត់ឲ្យហូបឆ្អែតហើយអញ្ចេះទៀត គាត់ប្រាប់ខ្ញុំថាមើលស្រូវធ្វើបានឆ្នាំហ្នឹង ឧទាហរណ៍ថាបាន១០គោនគាត់រាយការណ៍ទៅអង្គការតែ៧គោន ហើយគាត់លាក់ទុក៣គោន ហើយទៅអង្គការថាបើបាន៧គោនទុក២គោនឲ្យប្រជាជនទៅ យក៥គោនឡើង ហើយគាត់សល់៥គោនស៊ីអង្ករស៊ីអត់អស់ ដល់ពេលគាត់ថាតំបន់ខ្លះ តំបន់៤ តំបន់៥ ។

យឿតៈ នេះតំបន់៥ នេះយ៉ាប់ជាងគេបង្អស់ ។

វណ្ណៈ តំបន់៥សុទ្ធតែរាយការណ៍ថាបាន៧គោន រាយសុទ្ធតែ៨គោន ។

យឿតៈ អាហ្នឹងវាសុទ្ធតែរាយការណ៍យកគុណសម្បត្តិ ។

វណ្ណៈ ហ្នឹងហើយរាយការណ៍យកគុណសម្បត្តិ តាមពិតអត់មានអីស៊ីសោះ ដល់ពេលរាយអញ្ចឹងអង្គការថា អ៊ឺ! ឥឡូវបាន៨គោនឯងទុក២គោនចុះ យក៦គោនឡើង តាមពិតយើងរាយការណ៍អស់អាលីងហើយហ្នឹង មានអីហូបចុកទៀត ។

យឿតៈ ប្រជាជនអត់មានអីហូបទេ វាទុកស៊ីតែខ្លួនវាទេ ។

វណ្ណៈ ប៉ុន្តែស្រូវអីធ្វើបានដូចគ្នា?

យឿតៈ ធ្វើបានដូចគ្នា វាបញ្ជូនឲ្យគេអស់ទៅវាទុកស៊ីតែខ្លួនវាហ្នឹង ហើយយើងប្រជាជនហ្នឹងអត់ទៅ

វណ្ណៈ ម៉េចអញ្ចឹង?

យឿត៖ ខ្ញុំក្តៅណាស់ ពួកខ្ញុំអត់ណាស់ គ្មានកម្លាំងដើរទេ ហើយខ្ញុំថាបើសិនជា នេះប្អូនខ្ញុំនៅតែ៨-១០ថ្ងៃទៀតងាប់ហើយ ។

វណ្ណៈ ម៉េចអញ្ចឹង?

យឿត៖ ស្គមតូចមួយហ្នឹង ធំតែក្បាលហើយនឹងក្បាលជង្គង់ទេ ។

វណ្ណៈ នៅកុមារ?

យឿត៖ នៅកុមារតូចមួយហ្នឹង កំពស់ប៉ុនកូនតូចនេះ ។

វណ្ណៈ នៅក្នុងភូមិហ្នឹងវេទនាអត់មានអីហូប?

យឿត៖ វេទនាណាស់ គ្រាន់តែដាំបាយហ្នឹង ដើមចេកហាន់ហើយ កំសត់ណាស់ខ្ញុំឲ្យតែនិយាយ ។

វណ្ណៈ ចុះប្រធានសហករណ៍នៅហ្នឹងពីណាគេ?

យឿត៖ ប្រធានសហករណ៍នៅនេះមិនដឹងពីណាទេ មកនៅឈរជើងហ្នឹង ឈ្មោះប៊ុ ប៊ុន ប្រហែលជា មកពីខាងកំពង់ឆ្នាំងហើយ ។

វណ្ណៈ ចុះ តាប៊ុន អីហ្នឹងថ្ងៃក្រោយគេចាប់គាត់ដែរអត់?

យឿត៖ អត់មានទេ មានអ្នកណាចាប់ ដល់ពេលដល់ដែលគេថាឲ្យទៅវិញក៏ទៅ ដល់ពេលទៅបានប៉ុន្មានខែទេមកវិញ ។

វណ្ណៈ ចុះប្រធានសហករណ៍មុន តាប៊ុន ហ្នឹងពីណា អ្នកស្រុកអ្នកភូមិយើងមែន?

យឿត៖ ឈ្មោះប៊ុអីទេសក់រួញ ឈ្មោះអីទេខ្ញុំរកនឹកសិនភ្លេចបាត់ហើយ តាប៊ុន នេះចូលមកក្រោយពេលដែលចប់ហើយទេបាន តាប៊ុន ចូលមក ហើយមុន តាប៊ុន ហ្នឹងឈ្មោះអីទេ ដូចជាឈ្មោះ ធិ ។

វណ្ណៈ តែប្រធានសហករណ៍មុនគេចាប់គាត់ឬក៏អត់ទេ?

យឿត៖ គេមិនមែនចាប់ទេ គេជម្លៀសចេញទៅណាហ្នឹង ពេលដែលមកនៅឈរជើងនេះពួកនោះគេចអស់ ឈ្មោះ ប៊ុធិ ។

វណ្ណៈ មែនគេចទេ គេចាប់គាត់ទៅបាត់ទេ?

យឿត៖ ហ្នឹងហើយ ចាប់អស់ហើយ កាលហ្នឹងពួកខ្ញុំតូចៗ ពួកហ្នឹងចូលមកបាត់ពួកនេះ ហើយខ្ញុំមិនដឹងទេ គេថាគេផ្លាស់គ្នា ហើយពួកនេះគេផ្លាស់ឲ្យទៅនៅណាបានជាអាប៊ុនេះចូលមក ។

វណ្ណៈ អញ្ចឹងខ្ញុំចង់សួរបកទៅកន្លែងមីងវិញ កាលមីងនៅដើមពោធិ៍៣ដើមហ្នឹងមានឃើញមនុស្សដូចថាបាក់កម្លាំងស្លាប់អីហ្នឹងមានទេ?

យឿត៖ មាន ។

វណ្ណៈ មានដែរ?

យឿតៈ ចាំ! មាន គាត់ខ្វល់គាត់អីកាលហ្នឹង ឲ្យតែយើងបងប្អូនបង្កើតស្រីមួយប្រុសមួយឈរនិយាយគ្នាក៏មិនបានដែរ មុនដំបូងតឹងណាស់ ហើយខ្ញុំមិនហ៊ាននៅគេបណ្តើរមនុស្សយកទៅវ៉ៃចោល គេថាយើយខុសសិលធម៌ ។

វណ្ណៈ គ្រាន់តែនិយាយគ្នាហ្នឹង?

យឿតៈ ចាំ!

វណ្ណៈ អត់មានបានស្រលាញ់គ្នាមែនទែនផងហ្នឹង?

យឿតៈ ស្រលាញ់គ្នាអី ដែលថាបងប្អូនយើងបង្កើតដែលបែកគ្នា ដូចតែខ្ញុំហើយនឹងពូឯងអញ្ចឹងណាំសួរដំណើរទំនង ដូចឧបមាថាប្អូនខ្ញុំអញ្ចឹង ខ្ញុំសួរថាអូនឯងធ្វើការនៅណា ហើយស៊ីបាយឆ្អែតទេ ឈរនិយាយគ្នាតែមួយម៉ោងឬក៏២-៣ម៉ោងអីអត់បានទេ ចាប់តែយប់បន្តិចហ្នឹងចាប់បាត់ហើយ តែយើងខុសសិលធម៌ យើងស្រលាញ់គ្នាគេចាប់យើងយកទៅវ៉ៃចោលហើយ?

វណ្ណៈ ចុះកាលកន្លងមីងហ្នឹងគេមានឲ្យរៀបការអីដែរអត់?

យឿតៈ បើកវគ្គ ។

វណ្ណៈ បើកវគ្គមានដែរ?

យឿតៈ ចាំ! មាន ។

វណ្ណៈ ពេលការហើយគេឲ្យធ្វើការនៅហ្នឹងដដែល?

យឿតៈ ចាំ! បើកវគ្គម្តង៣០គូ ៥០គូ ។

វណ្ណៈ បើកវគ្គហ្នឹងសប្បាយទេ មីងធ្លាប់ទៅមើលទេ?

យឿតៈ ទេ ខ្ញុំមិនដែលទៅមើលទេ ខ្ញុំឮតែគេថា តែពេលដល់ថ្ងៃគេបើកវគ្គគេ ។

វណ្ណៈ មីងគេអត់ដែលរើសចំទេ?

យឿតៈ ទេ កាលហ្នឹងខ្ញុំនៅតូច គេស្នើរហ្នឹងខ្ញុំមិនដឹងអីទេ វាមិនមែនតូចប៉ុន្មានទេតែវាមិនដឹង មិនដឹងថាស្រលាញ់ហ្នឹងយ៉ាងម៉េច ចង់តែសើចនិយាយពីរឿងហ្នឹង មិនដឹងអីទេល្ងង់ណាស់មិនឆ្លាតដូចកូនក្មេងសព្វថ្ងៃទេ ។

វណ្ណៈ បើឧបមារថា មានគេមកស្នើរយកនារីហ្នឹងទៅ តែនារីហ្នឹងអត់ស្រលាញ់គ្នាទេ អាហ្នឹងធ្វើម៉េចទៅ?

យឿតៈ គេអត់យកទេ ។

វណ្ណៈ គេអត់បន្ទុំទេ?

យឿតៈ ចា៎! គេអត់បន្ទុំយើងទេ ។

វណ្ណៈ ហើយអញ្ចឹងអត់មានអក្តការបន្ទុំ ដូចថាបើយើងមិនយកគេយកយើងទៅវៃចោលអីអត់ទេ?

យឿតៈ អត់ទេ ។

វណ្ណៈ ឲ្យយើងទៅកន្លែងរៀងខ្លួនទៅ?

យឿតៈ បើឧបមារថា ប្ដីខ្ញុំស្រលាញ់ខ្ញុំហើយខ្ញុំថាខ្ញុំមិនយកទេ ខ្ញុំមិនទាន់យក បើមិនទាន់យកក៏ហីទៅ ស្រេចឯងទេគេអត់មានបន្ទុំយើងទេ មានតែខ្ញុំឃើញហ្នឹងភ្នែកផ្ទាល់ គេអត់មានបន្ទុំយើង ទេ ។

វណ្ណៈ ចុះពេលហ្នឹងកន្លែងនៅកងចល័តលើកទំនប់ដើមពោធិ៍៣ដើម ដូចថាកន្លែងដេកមានគ្រែ មានខ្នើយអីដែរទេ?

យឿតៈ ទៅរកគ្រែមកពីណា ឲ្យតែបានកៅស៊ូបាំងដេកលើដីហ្នឹងទៅ ។

វណ្ណៈ អញ្ចឹង?

យឿតៈ ចា៎! ដេកលើដី ហើយពេលភ្លៀងមកសាចហូរសើម អត់មានបានដេកទេ បើមានគ្រែខ្នើយស្រួលងាប់ហើយ អត់មានទេ ដូចតែយើងខ្ទមស្រែហ្នឹងឯង គេបោះជំរុំផ្ទាច់ៗទៅហើយដាក់នៅទៅ ម៉ាក្រុមៗដផ្ដែរគ្នាទៅ ។

វណ្ណៈ ហើយចុះមានពេទ្យមានអីដែរ?

យឿតៈ មាន ដល់ពេលយើងឈឺមិនស្រួលទៅយើងទៅស្នើរថ្នាំពីពេទ្យបាន ប៉ុន្តែមិនឃើញមានថ្នាំដូចយើងសព្វថ្ងៃផង ឃើញមានតែថ្នាំអាចម៍ទន្សាយប៉ុណ្ណឹងឯង ឲ្យមកម៉ាទូកដៃៗ មានតែថ្នាំនោះឯង អត់ដែលឃើញមានថ្នាំគ្រាប់ដូចយើងសព្វថ្ងៃនេះទេ អញ្ចឹងហើយបានជាខ្ញុំនិយាយប្រាប់កូនថា កូនអើយកាលនោះបើបានសម្លរដូចសព្វថ្ងៃនេះមិនដឹងឆ្ងាញ់យ៉ាងម៉េចទេ ស្លរម្ជូរដែលម៉ែទៅចល័តគេបើកស្លឹកគ្រៃ ស្លឹកគ្រៃគ្រឿងគេមានធំក្លិនម្ទេង ស្លឹកក្រូចស្រេច បើកតែស្លឹកគ្រៃ បើកតែម្ទេង ល្ងៀត អំបិល ហើយបន្លែមានត្រលាច ល្ពៅ ស្ពៃ អីមាន បន្លែដែលយើងដាំកើត បើថារឿងខ្ទឹមហើយនឹងម្សៅស៊ុបអត់មានទេ មានតែអំបិល មួយមុខហ្នឹងឯង ហើយនឹងប្រហុកមាន ហើយត្រីមាន ហើយមុនដំបូងដែលទៅនៅចាប់ ផ្ដើមធ្វើដើមពោធិ៍៣ដើម លើកទំនប់ដំបូងនោះមាន ។

វណ្ណៈ ដល់ពេលយូៗទៅខ្វត់ទៅៗ?

យឿតៈ ដល់ពេលយូៗទៅអត់មានទេ ដល់ពេលយូៗទៅគេអត់បានបើកឲ្យយើងទេ យើងទៅធ្វើការ មកវិញក៏តម្រៀបដូវគ្នា គេចូលទៅរោងបាយ បាយគេដួសរៀបដាក់ស្រេច ។

វណ្ណៈ ដល់ចុងក្រោយវៀតណាមចូលមក មីងអត់មានរត់ទៅជាយដែនអីទេ?

យឿតៈ ខ្ញុំមិនបានរត់ទៅណាទេ ខ្ញុំនៅនេះឯង ។

វណ្ណៈ រត់មកផ្ទះវិញ?

យឿតៈ ចាំ!

វណ្ណៈ ហើយចុះពួកនារតី ដូចជាពួកមកពីខាងនារតី មកគេអត់មានក្ដួងយើងនាំយើងទៅទេ?

យឿតៈ អត់ទេ គេទៅតែគ្នាគេទេ គេរៀបផ្ការាន់រៀបកាបូបទៅ គេថាគេទៅប្រជុំ ។

វណ្ណៈ គេភូតយើង?

យឿតៈ ចាំ! យើងអត់ដឹងទេ គេថាមិត្តឯងនៅមើលថែរក្សាផ្ការាន់យើងទាំងអស់ហ្នឹង កុំឲ្យអ្នកណាយករហេតរហូត ខ្ញុំទៅមិនយូទេ ខ្ញុំទៅប្រជុំ២-៣ម៉ោងអីមកវិញហើយ មិនដឹងថាវៀតណាមចូលទេខ្ញុំអត់ដឹងទេ ខ្ញុំនៅក្មេងដែរខ្ញុំមិនដឹងទេ គេថាទៅប្រជុំឯងក៏ជឿគេថាទៅប្រជុំ តាមពិតអានៅអញ្ចឹងយើងចានឆ្នាំងក៏មិនហ៊ានេះទេ អ៊ំ! យើងថ្ងៃនេះសម្រាកហើយ ប្រធានមិននៅយើងសម្រាកហើយ ។

វណ្ណៈ ហើយដល់ពេលត្រលប់មកស្រុកភូមិវិញ៧៩ហ្នឹងវៀតណាមចូលពេញភូមិហើយ ហើយនៅហ្នឹងក្រោយពេលវៀតណាមចេញចូលអញ្ចឹង ហើយខ្មែរក្រហមវាមិនទៅជាយដែន ហើយវាមកបន្តឡើងវៃហ្នឹងទៀតទេ?

យឿតៈ វាបន្តម្ដងទៀត ផ្ដើលរត់ អាប្រធានដែលមកនៅភូមិយើងនេះ ដល់ពេលវាចេញទៅហើយវាលួចមកទៀត គ្នាវា៤-៥នាក់ស្ពាយកាំភ្លើងមកខ្វាចឡើងរួញ អត់ហ៊ានជួបមុខវាទេរត់ពួន អស់ ។

វណ្ណៈ វាមកទៀត?

យឿតៈ វាមក កន្លែងវាធ្លាប់នៅ វាមកលេងមកសួរសុខទុក្ខ មិនដឹងវាមកយ៉ាងម៉េចបាននាំគ្នាខ្វាចហ្នឹងណាំ គេរត់គេចអស់ ។

វណ្ណៈ អញ្ចឹងដូចថានៅឡើងមកឆាឆៅម្ដងម្កាលទៀត?

យឿតៈ ចាំ! មានទៀត ។

វណ្ណៈ ដល់ឆ្នាំណាបានស្រួល ដូចថាលែងទាហានខ្មែរក្រហមព្រៃលែងមកហ្នឹង ដូចថាលែងចូលភូមិបាន?

យឿតៈ ដល់ពេលយួនចូលមកនៅនេះ ពេលវៀតណាមចូលមកនៅនេះទៅដល់ហើយឈប់ហើយស្រួលហើយ ។

វណ្ណៈ យួនបោះទីតាំងនៅនេះរហូត?

យឿតៈ ចា៎! វៀតណាមមកនៅស្រះនេះឯង ឈរជើងនៅស្រះនេះ ដល់ពេលនេះយើងស្រួលហើយ យើងអត់មានភ័យខ្លាចរត់ទៀតទេ ។

វណ្ណៈ ចុះវៀតណាមមកដែលធ្វើបាបយើងទេ?

យឿតៈ ទេ វៀតណាមមកនៅនេះអត់មានធ្វើបាបអីផង ។

វណ្ណៈ អញ្ចឹងអត់មានធ្វើបាបទេ?

យឿតៈ ចា៎! កំពុងតែនិយាយថាវៀតណាមមកនៅនេះឲ្យត្រកួន ពពាយ ស៊ីអត់អស់ទេឆ្ងាញ់ណាស់គេឆា ឆ្ងាញ់មែនណា៎ ឆាហើយយកមកឲ្យយើងស៊ីទៀតណា៎ ចៃហាយៗ ហូបទៅឆ្ងាញ់ណាស់ ហូបទៅ ចៃហាយ គេហៅចៃហាយ ហើយហៅឪពុកថាអឹយ៉ា ។

វណ្ណៈ គេចេះខ្មែរដែរ?

យឿតៈ ចេះ និយាយប៉ែឡាំៗ ដល់ពេលយួនចូលមកនៅនេះឯងបានស្រួល អត់មានអ្នកណាចូលមកលាយឡំទៀតទេ ហើយដល់ពេលថ្ងៃណាសភាពការណ៍មិនស្រួលគេប្រាប់ អឹយ៉ា ល្ងាចនេះមានការណាអឹយ៉ា គេថាកុំដេក អឹយ៉ា ល្ងាចនេះមានការ ហើយកូនអត់នៅទេ កូនទៅហើយ គាត់ត្រៀមឥវ៉ាន់ទៅអស់អាលីង ចេញទៅអស់ចេញទៅក្រៅថ្ងៃណាសភាពការណ៍ មិនស្រួលប្រាប់ហើយ ។

វណ្ណៈ អញ្ចឹងអត់នៅវិតទល់ជាមួយនេះទេ ខ្លាចដែរ?

យឿតៈ អត់ទេ ចេញទៅនោះ ចេញទៅឆ្ងាយពីភូមិ មិនមែនចូលមកវិលុកនេះទេ នៅក្រៅនៅយាមនៅខាងក្រៅ បាញ់គ្នាក្តុងក្តាំងយើងក៏រត់ក្រាបចូលពួនទៅណា៎ កុំតែបានពួកវៀតណាមចូលមកទេបានស្រួល មិនសូវភ័យខ្លាចចូលខ្លាចអី ។

វណ្ណៈ ចុះមកដល់ឥឡូវស្រួលមែនទែនហើយ?

យឿតៈ មកដល់ឥឡូវក៏នៅតែខ្លាចដែរ ។

វណ្ណៈ ខ្លាចអីគេ?

យឿតៈ ខ្លាចចោរ អត់មានខ្លាចអីទេខ្លាចចោរហ្នឹងឯងពេលយប់ព្រលប់អី ។

វណ្ណៈ	យើងការពារដែរទៅ?

យឿតៈ	យើងចេះតែខ្លាចទៅណា៎ ។

វណ្ណៈ	ប៉ុន្តែខ្លាចក្រែងវាឃើញផ្ទះយើងធំអញ្ចឹងវាមិនជឿ?

យឿតៈ	វាមិនជឿថាយើងក្រទេ តាមពិតយើងមិនមានទេ ។

វណ្ណៈ	ឥឡូវខ្លាចចោរវិញ?

យឿតៈ	ចា៎! លែងខ្លាចអីហើយខ្លាចតែចោរ ។

វណ្ណៈ	អញ្ចឹងនៅស្រុកហ្នឹងមានចោរប្លន់ដែរ?

យឿតៈ	វាមិនទាន់មានទេ តែយើងចេះតែខ្លាចទៅណា ។

វណ្ណៈ	ចុះអ្នកស្រុកអ្នកភូមិហ្នឹងភាគច្រើនមានកូនមានចៅអីឲ្យទៅរកស៊ីស៊ីឈ្នួលនៅថៃ ឬក៏ធ្វើចំការរកស៊ីនៅនេះ?

យឿតៈ	ទៅថៃ កូនខ្ញុំទៅ ធ្វើប៉ាស្ព័ទៅ៣នាក់ តែដល់ពេលនេះវាមិនបានទៅ៣នាក់ បានទៅតែ២នាក់ហើយសល់១ ។

វណ្ណៈ	ចង់ទៅថៃដែរ?

យឿតៈ	ចងទៅថៃ មិនដឹងរកអីបានអូនឯងមើល ធ្វើស្រែវាស្រែបន្តិចបន្តួចហើយធ្វើវាមិនកើតបានតែម៉ាស៊ីៗហ្នឹង ហើយស៊ីមិនគ្រប់ទៀត ។

វណ្ណៈ	ហើយ២នាក់ដែលទៅថៃហ្នឹងយ៉ាងម៉េចទៅ ទើបតែទៅទេមែនទេ?

យឿតៈ	ទៅបាន៣ខែជាងហើយ ប៉ាស្ព័រយើងទៅខាងផ្លូវច្បាប់ ហើយបើយើងទៅអត់ច្បាប់ហ្នឹងវាពិបាកប្រគេងប្រគាង រត់មិនរួចរត់អីទៅ ដល់ពេលនេះយើងធ្វើផ្លូវច្បាប់ ធ្វើនៅភ្នំពេញមុនដំបូងយើងធ្វើអស់ម្នាក់១៥០ដុល្លា គេយកណា៎ ដល់ពេលទៅធ្វើការកន្លែងក្រុមហ៊ុននោះគេកាត់យកពីយើងទៀត៣ខែ ។

វណ្ណៈ	កាត់៣ខែទៀត?

យឿតៈ	ចា៎! ដល់ពេលធ្វើ៣នាក់ កូនខ្ញុំថាទៅទាំង៣នាក់ព្រោះបានដុបងប្អូនវាឈប់រៀនអស់ហើយ យើងអត់មានសមត្ថិភាពឲ្យកូនរៀនទេ ។

វណ្ណៈ	អញ្ចឹងផុតពី៣ខែមកយើងវិញ?

យឿតៈ	ចា៎! កាត់យក៣ខែរួចទៅបានៗយើង ។

វណ្ណៈ	ឥឡូវទើបតែបាន៣ខែទេ?

យឿត: បាន៣ខែ គេតេមកប្រាប់ថ្ងៃមិញថា ម៉ែអើយគេកាត់រួចហើយ ខែក្រោយបានយើងហើយ ដល់ពេលមួយអត់បានទៅនេះខ្ញុំសួរថា វាមិនបានទៅធ្វើផ្ទាល់នៅក្រុមហ៊ុន ធ្វើតាមខ្សែរយៈមេខ្យល់គេយកទៅ

ដល់ពេលយើងគេទៅលេខក្រុមហ៊ុនមិនដឹងថាលេខក្រុមហ៊ុនហ្នឹង ឈ្មោះអី ។

វណ្ណៈ: ឥឡូវសួរកូនទៅ ថាទៅធ្វើហ្នឹងស្រួលឬក៏ពិបាក?

យឿត: មិនអីទេថាស្រួល ឲ្យតែបានទៅទៀតវាអាចតស៊ូបាន ធ្វើការកន្លែងបកបង្កង វានៅម្ងប់ ហើយធ្វើការគេមានម៉ោងមានពេលគេសម្រាក កន្លែងក្រុមហ៊ុនណា៎ មិនមែនធ្វើដូចអាអ្នកសម្ភាសន៍ថ្ងៃមិញ អាហ្នឹងយ៉ាប់ណាស់ព្រោះធ្វើដូវកាត់ ហើយយើងទៅយើងអស់ទន់ច្រើនព្រោះយើងធ្វើដូវច្បាប់ ។

វណ្ណៈ: តែបើយើងទៅលាក់លួចរត់ទៅយើងស៊ីឈ្នួលតាមផ្ទះគេ យើងអត់មានបានចេញមុខចេញមាត់ក្រុមហ៊ុនទេ?

យឿត: អត់ទេ យើងទៅដូវកាត់វាអត់ស្រួលដូចយើងទៅក្រុមហ៊ុនទេ វាពិបាក បើយើងធ្វើការធ្វើៗទៅ ហ៎! តម្រួតមកហើយក៏រត់ទៅ នឹងឃើញថាបើកូនទៅអាដូវអត់ច្បាប់វាពិបាកបានឲ្យកូនធ្វើច្បាប់ទៅទាំង៣នាក់ តែទៅបានតែ២នាក់ នៅសល់មីមួយនេះគេថាចាំឆ្នាំមុខតវ៉ាយកលុយវិញគេថាមិនអាចយកលុយបានទេ តែបង់ហើយមិនបានទេ ។

វណ្ណៈ: បង់លុយហើយយកវិញអត់បានទេ?

យឿត: អត់បានមកវិញទេ អស់១៥០ចោលទៅ ។

វណ្ណៈ: ក្រែងគិតទាំង៣នាក់ ដល់ពេលបានគឺបានតែ២នាក់?

យឿត: គេឲ្យឈ្មោះមកមានតែ២នាក់ ហើយម្នាក់ទៀតគេថាចាំវគ្គក្រោយ ហើយក៏ចាំវគ្គក្រោយរហូតដល់ពេលនេះនៅមិនបានទៅទៀត ។

វណ្ណៈ: អញ្ចឹងខ្ញុំកាត់មីងបន្តិច ចូលដល់សព្វថ្ងៃហ្នឹងមីងដឹងរឿងតុលាការកាត់ទោសអ្នកដែលធ្វើបាបយើង ដូចជាអ្នកថ្នាក់ដឹកនាំជាន់ខ្ពស់កំពូលហ្នឹង មីងដែលស្តាប់វិទ្យុដឹងថារឿងការកាត់ទោសខ្មែរក្រហមហ្នឹងមីងដឹងទេ?

យឿត: មិនចាំទេ ហើយយើងមិនដែលមានវិទ្យុស្តាប់ទេ ទើបតែមាន ទើបតែទិញបានប៉ុន្មានថ្ងៃហ្នឹងយកមកស្តាប់ ។

វណ្ណៈ: ចុះមីងខ្ញុំសួរបន្តិច ដូចថាសព្វថ្ងៃនេះនៅ តាអៀង សារី តាប៉ុល ពត គាត់ស្លាប់ហើយណា៎ ហើយតានួន ជា តាខៀវ សំផន ហើយនឹងប្រពន្ធអៀង សារី សព្វថ្ងៃគេឃុំខ្លួនគាត់នៅ

តុលាការដើម្បីធ្វើការកាត់ទោសមេដឹកនាំជំនាន់ប៉ុល ពត និយាយទៅមេថ្នាក់ដឹកនាំកំពូលហ្នឹង យើងក៏មិនដែលស្គាល់ដែរ ពីរជំនាន់ហ្នឹងគេដឹងថាអង្គការ ហើយមិនដឹងមុខអង្គការណា ឈ្មោះអីទេ?

យឿត: ខ្ញុំមិនដែលស្គាល់ទេ ។

វណ្ណៈ អញ្ចឹងដល់ពេលមានតុលាការកាត់ទោសពួកគាត់ដែលបានធ្វើបាបយើងអញ្ចឹង តើមីងគិតថាគេកាត់ទោសគាត់អញ្ចឹងជាការត្រឹមត្រូវឬក៏មិនត្រឹមត្រូវ អាហ្នឹងបើតាមមីងយល់?

យឿត: ត្រឹមត្រូវណាស់ហើយអូនអើយ កំពុងតែថានិយាយហ្នឹងចង់ស្រក់ទឹកភ្នែក ដូចថាវាឆ្អែតធ្វើបាបមិនធម្មតាទេ មើលទូរទស្សន៍ថ្ងៃមុនដែរ ឃើញដែរកន្លែងគេថាតាមួយគាត់បង់កនឹងកន្សែង ហើយគាត់និយាយពីតវ៉ា ។

វណ្ណៈ អញ្ចឹងខ្ញុំដូចជាអស់សំនួរអីសួរមីងហើយ អញ្ចឹងខ្ញុំអរគុណមីងច្រើនហើយ ។

យឿត: ចា៎!

«ចប់»